## វគ្គសិក្សាស្តីពី

# ផលិតកម្មដំណាំត្រាវ

## សំរាប់ផ្សព្វផ្សាយកសិកម្ម

បង្រៀនដោយ : លោក ទេព ចាន់ដារ៉ា



A

011 955 250



B

2007-2008

Kg Speu 20-22 មិថុនា 2007

# វគ្គសិក្សាស្តីពី

ម.ព.ឯ.ក AIDOC
Code: 107-007
Date:
Donated by:

# ផលិតកម្មដំណាំត្រាវ

## សំរាប់ផ្សព្វផ្សាយកសិកម្ម

បង្រៀនដោយ : លោក ទេព ចាន់ដារ៉ា





011 955 250

2007-2008

## មាតិកាអត្ថបទ


**១.ប្រវត្តិនិងស្ថាភាពដាំដុះសារៈប្រយោជន៍នៃដំណាំត្រាវ**.................................................................១

**២.លក្ខណៈរូបសាស្ត្រដំណាំត្រាវ**...............................................................................................១

ក.ប្រពន្ធ័រឹស.................................................................................................១

ខ.ដើម ..................................................................................................................២

គ .ធាង...................................................................................................................២

ឃ .ផ្កា ...................................................................................................................២

ង.ស្លឹក ..................................................................................................................២

ច.មើម ..................................................................................................................២

**៣.លក្ខណៈបរិស្ថាន**...........................................................................................................៤

ក .សីតុណ្ហភាព ..........................................................................................................៤

ខ.ពន្លឺ.......................................................................................................................៤

គ.របបទឹកភ្លៀង..........................................................................................................៤

ឃ.ដី .......................................................................................................................៤

**៤.បច្ចេកទេសដាំដុះ**.............................................................................................................៥

ក.ការរៀបចំដី..............................................................................................................៥

ខ.ការដាំដុះ.................................................................................................................៥

**៥.ពូជ.** COLOCASIA ANTIQUORUM EDDOE..........................................................៨

**៦.ពូជ.** XANTHOSOMA SAGITTIFOLIUM ..........................................................៨

៧.ជំងឺនិងសត្វល្អិត..........................................................................................................៥

ជំងឺRoot rot.................................................................................................................៥

៨.ការប្រមូលផល..........................................................................................................១០

# ដំណាំត្រាវ

ត្រាវស្ថិតនៅក្នុងគ្រួសារ Family Name : Araceae

ឈ្មោះភាសារអងគ្លេស English Name: Taro

ឈ្មោះវិទ្យាសាស្ត្រScientific Name: Colocasia eseulenta

**លក្ខណពូជ**

- Colocasia esaulenta ត្រាវស្លាគេនិយមបរិភោគ
- Colocasia antiquorum ត្រាវទឹកជាចំណើសត្វវារមាស់
- Xanthosoma Sagittifolium ( កូនដើមតូច ស៊ឹកឆែក

## ១~ ប្រវត្តិស្ថានភាពដាំដុះនិងសារៈប្រយោជន៍របស់ដំណាំត្រាវ

ដំណាំត្រាវបានលូតលាស់នៅអាស៊ីអាគេយ៍ ហើយត្រូវបានដាំមុនគេបង្អស់នៅប្រទេសចិន បន្ទាប់មកនៅជប៉ុន និង រាលដាលទៅដល់តំបន់ខាងកើតនៃសមុទ្រមេឌីទែរ៉ាណេ ហើយឆ្លងកាត់អាហ្វ្រិក ទៅ Guinea ។ ប្រភេទត្រាវផ្សេងៗ ទៀត Dasheen មានដើមកំណើតនៅ Columbian និង ត្រូវបានដាំដុះមុនគេបង្អស់ឥណ្ឌា និង ជាដំណាំដែលប្រជាជនឥណ្ឌានៅភាគខាងត្បូងនិមយដាំបំផុត ។ នៅអាហ្វ្រិកខាងត្បូងប្រជាជននិយមដាំយកមើមបរិភោគ ដូចជាចៀន ស្ងោរ និង ចិតស្តើងៗបាសអោយស្ងួត បុកធ្វើម្សៅ និង កែច្នៃធ្វើនំផ្សេងៗ ។ មិនថាតែប្រជាជនអាហ្វ្រិកទេដំណាំត្រាវជាអាហារសំខាន់បំផុតសំរាប់មនុស្សជាតិ គេអាចយកដើមត្រាវទៅធ្វើជាបង្អែម ឬ ស្ងោរហូបធម្មតាក៏បានគេអាចយកមើមរបស់វា ឬ ធាង ធ្វើជាបន្លែសួរបរិភោគ ។ ដំណាំត្រាវសំបូរដោយសារធាតុដែលគេសង្កេតឃើញសារធាតុមួយចំនួននៅក្នុងមើម របស់ពួក Dasheen ជាតិទឹក ៦៣-៨៥ ភាគរយ. ប្រូតេអ៊ីន ១.៤-៣.០ ភាគរយ. ខ្លាញ់ ០.២-០.៤ភាគរយ. កាបូនអ៊ីដ្រាត ១៣-២៩ភាគរយ. ជាតិសរសៃ ០.៦-១.២ភាគរយ. ជាតិផេះ ០.៦-១.៣ភាគរយ និង វីតាមីន B និង C ចំណែកឯស្លឹកមានផ្សំដោយជាតិទឹក ៨៧.២ ភាគរយ. ប្រូតេអ៊ីន ៣.០ភាគរយ ខ្លាញ់ ០.៨ភាគរយ. កាបូនអ៊ីដ្រាត ៦.០ភាគរយ. ជាតិសរសៃ ១.៤ភាគរយ. ផេះ ១.៦ភាគរយ ហើយនៅស្លឹកត្រាវជាប្រភពនៃវីតេមីន C ។ចំណែកនៅប្រទេសកម្ពុជាវិញដំណាំត្រាវជាដំណាំមួយដែលកសិករនិយមដាំស៊ុះសាយនៅក្នុងប្រទេស ពិសេសនៅតាមតំបន់តាមមាត់ទន្លេមេគង្គ ទន្លេបាសាក់ និង ជុំវិញបឹងទន្លេសាប ។ ខេត្តផ្សេងៗទៀត ក៏មានដាំបន្ទាប់បន្សំក្នុងលក្ខណៈគ្រួសារ ។

## ២~ លក្ខណៈរូបសាស្ត្ររបស់ប្រភេទត្រាវ Colocasia esculenta ( Dusheen )

**ក-ប្រពន្ធ័ឬស:** ឬសជាផ្នែកមួយនៃសរីរាង្គរុក្ខជាតិ ដែលវាមានតួនាទីសំខាន់បំផុតសំរាប់ស្រូបយកទឹក និងសារធាតុចិញ្ចឹមពីក្នុងដី និង ទ្រទ្រង់ដើមដង ។

ប្រព័ន្ធឬសរបស់ដំណាំត្រាវ ជាប្រភេទឬសស្ទៃដែលវាដុះចេញពីថ្នាំងរបស់ដើមមើមរបស់វាគ្មានឬសកែវទេ ។ ឬសរបស់ត្រាវវាចាក់ចុះទៅក្នុងដីបានរាក់ ដូចនេះវាទាមទារធ្វើដីអោយបានល្អ ដើម្បីអោយវាចាក់បានជ្រៅដើម្បីស្រូបយកជីវជាតិ ។ នៅលើឬសស្ទៃនេះមានឬសតូចឆ្មា១ ដូចជារោមដុះពីលើ គេហៅថាឬសជញ្ជក់ដែលវាមានតួនាទីយ៉ាងសំខានក្នុងការស្រូបយកជីវជាតិពីក្នុងដី ។ ឬសចាស់មានពណ៌ផ្កាឈូក. ដ្យាម៉ែត្រឬស ៣-៧មម. ប្រវែងឬសសំខាន់១ (ធំ) ៣៥- ៤៥សម ឬសបែកខាង១មានប្រវែងរហូតដល់ ២ម ។ ឬសត្រាវនៅតូចខ្ចី មានពណសស្លេង ។

**ខ-ដើម** ត្រាវជាប្រភេទដើមមើមដែលដុះនៅកុងដី ។ វាមានរាងប៉ោងមូល ហើយស្ទួចចុង ដើមមានកំពស់ ៦០-៩០ ស.ម មើមសំបូរដោយអាមីដុង ហើយសាច់របស់វាមានពណ៌ស កូលាប ឬក្រហមព្រឿង ។ ផ្នែកខាងក្រៅមានពណ៌រាងក្រមៅ មានលក្ខខណ្ឌ័ល វាលូត លាស់យ៉ាងរហ័ស បង្កើតជាសឹកដូចដើមមេវាដែរ ។ នៅពីលើថ្នាំងរបស់ត្រាវ គេឃើញមានស្រកាសឹក (រុចាលេ-លពាថ) ដុះតាមថ្នាំងរបស់វា ។

**គ-ធាងត្រាវ** ធាងត្រាវស្ថិតនៅចនោះដើម (មើម) និងសឹក ។ វាមានពណ៌បៃតង មានប្រវែង ៣០-៦០ ស.ម ។ ផ្នែកខាងកុងរបស់ធាងមានសភាពស្ពោត ។

**ឃ-ផ្កា** ផ្កាត្រាវមានលក្ខណដំណើរលំអងកាត់ និងលំអងឯង

**ង-សឹក** ដំណាំត្រាវវាមានសឹក រាងជាខែល ហើយមនពណ៌បៃតងព្រលែត ឬបៃតងក្រមៅ រូបរាងសឹកមានលក្ខណ ខុសគាដែរទៅតាមពូជ ។ ហើយទំហំសឹកក៏មានការខុសគាទៅតាមពូជដែរ ។

**ច-មើម**មើមត្រាវមានរាងដូចបំពងស៊ីឡាំងមានប្រពន្ធ័រសដុះជុំវិញនិងមានស្នាមពក១ដែលជាកត្តាអោយវាដុះពន្លកបាន ។




*Fig. 61* - Xanthosoma brasiliense.



*Fig. 74 - Organes souterrains du Madère* (Colocasia antiquorum).



# ៣. លក្ខណៈបរិស្ថាន

**ក. សីតុណ្ហភាព** ដំណាំត្រាវមិនអាចលូតលាស់ និងធន់ទ្រាំនៅសីតុណ្ហភាពទាបជាង ១០អង្សាសេទេ។ វាត្រូវការលូតលាស់ និងបង្កើតមើមប្រសើរបំផុតចំពោះសីតុណ្ហភាពពី ២៥-២៨អង្សាសេ ។ចំពោះសីតុណ្ហភាពខ្ពស់លើសពី ២៨អង្សាសេ ដំណាំត្រាវមិនអាចដុះលូតលាស់បានលទេ ។

**ខ.ពន្លឺ** ពន្លឺថ្ងៃក៏ដូចជាសីតុណ្ហភាពដែរវាមានសារសំខាន់ណាស់សំរាប់ការលូតលាស់ព្រោះវាត្រូវការពន្លឺដើម្បីធ្វើរស្មីសំយោគ ។

ដំណាំត្រាវគេចាត់ទុកជាដំណាំដែលទ្រូវការពន្លឺពីមធមទៅខ្សោយ ។ គឺវាត្រូវការពន្លឺតិចជាងដំឡូងជ្វា និងដំឡូងឈើ ។

**គ.របបទឹកភ្លៀង** ដំណាំត្រាវជាដំណាំដែលត្រូវការនូវសំណើមច្រើន ពិសេសគឺនៅពេលដំណាំនៅតូច ដូចនេះហើយទើបកេទាមទារ ប្រើកំទេចកំទីគ្របដីដើម្បីការពារសំណើម ។ ប្រពន្ធ័ឫសរបស់ ជ្យូល្យចាសិា ជាដំណាំដែលត្រូវការទឹកច្រើនបំផុត ធន់ទ្រាំនឹងការដកដង្ហើម ។ ជួនកាលគេដាំវាក្នុងទឹកលាយជាមួយដំណាំស្រូវ គេត្រូវដក់លទឹក អោយត្រឹមកំពស់ ៤ ស.ម ខាងលើគល់ដើម ។

ចំពោះរបបទឹកភ្លៀង ដំណាំត្រាវអាចលូតលាស់លចំពោះតំបន់ដែលមានបរិមាណទឹកភ្លៀងធាក់ពី ១៥០០-២៥០០ម.ម ក្នុងមួយឆ្នាំ ។

**ឃ. ដី** ដោយដីជាគ្រឿងទ្រទ្រង់ និងផ្ទុកចំណីអាហារធមជាតិ របស់រុក្ខជាតិ ដីមានតួនាទីដសំខាន់សំរាប់ទ្រទ្រង់ជីវិតរុក្ខជាតិ ។ ដីជាជម្រុកផ្ទុក ទឹក និងអាហារ ព្រមទាំងអាចជាបច្ច័យនៃការប្រែប្រួលបែកពីគ្នានៃផលិតផលត្រាវដោយយោងទៅលើលកណសម្បតិនៃអតិរូប និងសកមភាពគីមី ។

-ដីដែលសមស្របសំរាប់ដំណាំត្រាវ គឺដីដែលមានសំណើមខ្ពស់ ដីស្រាល មានជីជាតិ ហើយដំណាំនេះរស់ដោយស្រូបយកទឹក ដែលដក់ក្នុងស្រទាប់ដីខ្ពស់ ។

-ដំណាំនេះអាចដាំបានលើដីដែលមាន pH ៥.៥-៦.៥ ។

-នៅក្នុងប្រទេសកម្ពុជាយើង ដីដែលលសំរាប់ដំណាំត្រាវជាដីប្រភេទល្បាប់ខ្សាច់តាមដងទន្លេមេគង្គ ទន្លេ បាសាក់ និង ជុំវិញបឹងទន្លេសាប និងប្រភេទដីកណ្តៀង ។

# ៤. បច្ចេកទេសដាំដុះ

ក.ដំណាំឆ្លាស់ជាមួយត្រាវ :ដើម្បីទទួលបានទិន្នផលខ្ពស់ និងផលចំនេញច្រើន គេអាចដាំត្រាវជាលក្ខណៈឆ្លាស់ជាមួយដំណាំផ្សេង ។វិធីដែលគេដាំឆ្លាស់ជាមួយដំណាំនោះ គេអនុវត្តតាមរបៀបផ្សេងៗ :

- ការដាំត្រាវបង្វិលជាមួយដំណាំស្រូវ ពោលគឺគេដាំស្រូវនៅរដូវវស្សា ហើយបន្តពីស្រូវគេរៀបចំដាំត្រាវបនទៀត

- ដាំត្រាវជាលក្ខណៈចំរុះជាមួយដំណាំផ្សេងៗទៀតគឺ ប៉េងប៉ោះ សណ្តែកដី សណ្តែកបាយ ឬក៏បន្លែ ផ្សេងៗទៀត ។

**ក.ការធ្វើដី:** ការរៀបចំដីចំពោះដំណាំត្រាវជាបញ្ហាមួយចាំបាច់បំផុតព្រោះវាធ្វើអោយដីមានទំរង់ល្អបង្កលក្ខណៈងាយស្រួលដល់ការលូតលាស់ និងចាក់ឬសដើម្បីស្រូបយកនូវសារធាតុនៅក្នុងដី ។ ការធ្វើដី ធ្វើអោយសំនើក្នុង ដីល្អ ហើយសំបូរទៅដោយអុកស៊ីសែន ក្រៅពីនោះវាបំផ្លាញនូវស្មៅចង្រៃ និងកាកសំណល់ផ្សេងៗអោយរលួយឆាប់ ។ ដីដែលមានលក្ខណៈសមស្របសំរាប់ដំណាំត្រាវគឺប្រភេទដីល្បាប់ខ្សាច់ និងល្បប់កណ្តេង ។ផះ ដីដែលសមស្របគឺ៥.៥-៦.៥។ គេភ្ជួដីយ៉ាងតិចពីរទៅបីដង ហើយមានជំរៅ ២០-២៥ស.ម ។ ក្រោយពីភ្ជួហើយ គេត្រូវរាស់ដីអោយបានម៉ដល្អ អោយមានសភាពរាបស្មើ ហើយត្រូវប្រមូលនូវស្មៅ និងកាកសំណល់អោយអស់ ។

ចំពោះការរៀបចំដីដាំត្រាវ គេអនុវត្តខុសគ្នាទៅតាមតំបន់ និងតាមរដូវ :

-ការលើករង : គេនិយមធ្វើនៅរដូវវស្សា ពិសេសមាននៅក្នុងខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ។ គេលើកជារងធ្វើក្រោយពីរាស់ ដោយមានប្រវែងទទឹង ០.៨-១ ម កំពស់រង ២០-៣០ស.ម ហើយបណ្តោយអាស្រ័យតាមប្រវែងដី ។

**ខ_ការដាំដុះ**

-គេនិយមដាំត្រាវនៅដើមរដូវភ្លៀង

-ក្រោយពីកប់កូនត្រូវយកកំទេចចំបើងគ្របគល់ការពារការរោលកូន

-គេដាំត្រាវក្នុងចន្លោះដែលជីកអន្លង់ពីរងមួយទៅរងមួយទៀត២ម

-មានចំងាយគុម្ពត្រាវពី ៥០ស.ម X ១ម **ចំពោះត្រាវស្វាត្រាវគោក**

-គេត្រូវការពូជ ១.៥-២តោនក្នុង១ ហ.ត

-គេត្រូវការពូជ ២០០០០កូនក្នុង១ ហ.ត

**- ចំពោះត្រាវទឹក**

-គេត្រូវការពូជ ១០០០០កូនក្នុង១ ហ.ត

-គេដាំក្នុងចំងាយ ១.ម X ១ម

ការជ្រើសរើសពូជ គ្មានជំងឺ និងសត្វសត្វល្អិត

មើមមានទំងន់ ៦០-១៥០g ( កូនមើមតូចៗហើយស្លឹកធំ )

-ការបន្តពូជ : បន្តពូជតាមមើម និងកូន

-របៀបដាំ :

-ដាំលើដីរាបស្មើ

-ជីកចុងចង្អូរ ( ការដាំចង្អូ )

-ការជីកចុងជាខ្នើយ ( ដាំនៅចន្លោះខ្នើយ)

-ដាំក្នុងរណ្តៅ អង្កត់ផ្ចិត ១២-១៥ស.ម ជំរៅ ២០-២៥ស.ម

-ចន្លោះគុម្ព ៦០ x ៦០ស.ម ឬ ៧៥ x ៧៥ស.ម

ការបណ្តុះកូន :

-ការជ្រើសដីបាតបឹងត្រពាំង

-ការកប់មើមដាំ ៥-៧ស.ម បើដើម ១៥-២០ស.ម

-ដាំហើយស្រោចទឹកគ្របចំបើង

-អាយុ ១៨-២០ថ្ងៃ ( ស្លឹក២-៣)ជីកយកទៅដាំនៅចំការ

-ប្រភេទត្រាវដាំយកធាង ៣ខែ ( អោយជ្រូក)

-ប្រភេទត្រាវដាំយកមើម ៦-៧ខែ

-ស្លឹកប្រែជាលឿងហើយងាប់

-ការដាំដោយបុករណ្តៅ : គេអាចអនុវត្តនៅរដូវប្រាំង ពិសេសកសិករមួយនៅតាមដងទន្លេបាសាក់ និងទន្លេមេគង្គ មានក្នុងស្រុកស្អាង ខេត្តកណ្តាល ។ ក្រោយពីធ្វើដីអោយម៉ដគេក៏យកសំរាម ឬស្លឹករុក្ខជាតិក្រៀម ឬគល់ជព្រាំង មកក្រាលពីលើដីនោះអោយមានកំពស់ ២-៣ស.ម ។ ក្រោយមកយើងក៏ធ្វើការស្រោចទឹកអោយជោគជាំសព្វល្អទើបគេ យកអង្រែមកបុកជារណ្តៅ ។ ត្រាវមានអង្កត់ផ្ចិត១២ -១៥ស ម ជៅរៅ ២០-២៥ ស ម ហើយចំងាយពីរណ្តៅមួយទៅ រណ្តៅ ៦០សម ៦០ សម រឺ ៧៥ សម ៧៥សម ។

ជិតប្រភពទឹក ពិសេសដីបាតព្រែក បាតបឹង ។ គេអាចលើកកូនខ្នាតតូចៗ ឬពុំបាច់លើកជារងក៏បាន ។ គេរាស់ដីអោយ មានភាពរាបស្មើ ហើយយកកូនត្រាវមកដាំតំរៀបលើដី ។ គេអាចយកកំទេចកំទីមកគ្របពីលើ ។ កូនត្រាវត្រូវធ្វើការ ស្រោចស្រពបានទៀងទាត់ ។ កូនត្រាវអាយុ ១៨-២០ថ្ងៃ គឺមាន២-៣សន្លឹក គេចាប់ដកវាយកទៅដាំ ។ ការកប់ដើមដាំ ក្នុងជំរៅ៥-៧ស.ម ។ បើដើមត្រូវដាំក្នុងជំរៅ ១៥-២០ស.ម ។

តាមឯកសារស្រាវជ្រាវមួយចំនួន គេបញ្ជាក់ថានៅប្រទេសដទៃទៀត គេយកមើមដែលធំៗល្អធ្វើជាពូជដើម្បីបណ្ដុះកូន ។ ផ្នែកខាងលើ និងកណ្ដាល ត្រូវបានគេយកមកប្រើប្រាស់ ។ ផ្នែកកណ្ដាលត្រូវបានគេយកមកកាត់ជាដុំៗតូចៗ មានភ្នែក២ឬ៣ និងទំងន់ពី ២០-៣០ក្រាម ទៅបណ្ដុះ ។

# ៥.COLOCASIA ANTIQUORUM EDDOE

នៅតំបន់ខាងលិច **eddoe** វាបង្កើតមើមតូចៗជាប់ដើមធំទៀត គឺនៅគ្រប់ជ្រុងនៃដើមធំ ( ជុំវិញមើមធំ ) ។ មើមតូចៗទាំងនេះត្រូវបានគេហូបដែរ ។

ប្រភេទ Antiquorum b¤ Eddoe ត្រូវបានជំរើស និងរីកចំរើន ។នៅប្រទេសចិន និងជប៉ុនពីដំបូង ជ ។សេចុលានតា ដែលបានស្គាល់រាប់ពាន់ឆ្នាំមកហើយ ។ នៅតំបន់ខាងលិចពួក Eddoe នេះបានដុះលូតលាស់ច្រើនណាស់ ហើយពួកប្រភេទ នេះជួនកាលគេហៅថា(Chineseenddoe) ។នៅផ្នែកខ្លះនៃប្រទេសអាឡឺម៉ង់គេហៅថា (Malangas)ដូចគ្នានឹងDasheenដែរលើកលែងតែមើមដែលមានចំនួនច្រើនជាងDasheen ហើយមានទំរង់ជាចង្កោម ដែលដុះពន្លំជុំវិញមើមធំ មេ ។

-ការបន្តពូជ : បន្តពូជដោយមើមតូចៗ ឬមើមធំដែលមានទំរង់ ៦០-១៥០ក្រាម ហើយកប់វាទាំងអស់ក្នុងជំរៅ ៥-៧.៥ស.ម ។

-ការដាំដុះ : Enddoes ប្រពន្ធ័ដាំដុះរបស់វា ៦០-៧៥ស.ម ។ នៅតំបន់ខាងលិចគេតែងតែដាំលាយជាមួយដំណាំផ្សេងៗដូចជា សណ្តែក ពោត ។ល។ ឬចំការអំពៅ ហើយគេដាំនេះតែងតែប្រើជី Orzanic លាយបន្ថែម ។ ត្រាវមើមពេញវ័យយល្អក្នុងអាយុ ៥-៦ខែ ។ មើមរបស់វាត្រូវជីកយ៉ាងប្រុងប្រយ័ត្ន ព្រោះមើមទាំងនេះអាចដាច់ នៅក្នុងដីរហូតដល់រដូវ ក្តៅ ។ មើមរបស់វាអាចរក្សាទុកមិនយូរប៉ុន្មាន គឺក្នុងរយៈពេល៣-៤ខែ ដោយធ្វើវាអោយស្ងួត ។

# ៦. XANTHOSOMA SAGITTIFOLIUM

មើមរបស់វាគេប្រើប្រាស់ដោយយកវាទៅស្ងោរហូប ។ នៅតំបន់ខាងលិចពពួក Xanthosoma នេះត្រូវបានប្រជាជនមិនសូវនិយមចូលចិត្តដូចដំឡូងជ្វាទេ ។ ធាតុផ្សំគីមីរបស់វា ទឹក ៧០-៧៧% ប្រូតេអ៊ីន ១.៣-៣.៧% ខ្លាញ់ 0.២-0.៤% កាបូនអ៊ីត្រាត ១៧-២៦% សរសៃ 0.៦-១.៩% ផេះ 0.៦-១.៣% ។ ប្រភេទ Xanthosoma ត្រូវការកំពស់ទឹកភ្លៀង និងសំណើមខ្ពស់ វាដុះលូតលាស់នៅកន្លែងដែលមានម្លប់តិចតែវាមិនត្រូវការម្លប់ខ្លាំងពេកទេ ។

ត្រាវប្រភេទ Xanthosoma នេះមានដើមខ្លីមើមរបស់វាដុះចេញពីគល់ដើម ជាមួយដើមរបស់ត្រាវនេះតូចៗ មានប្រវែង១៥-២៥ស.ម ក្នុងត្រាវ១ដើមអាចបង្កើតមើមពី ១០ឡើងទៅ ។ ផ្ការបស់វាដុះចេញពីក្នុងបណ្តូលស្លឹក មានត្រាវមួយចំនួនកំរចេញផ្កាណាស់ ។ ត្រាវនេះបន្តពូជដោយដើម អាចបន្តពូជដោយមើម ឬក្តៀង ។

ការដាក់ជី :ជីដែលប្រើលើដំណាំត្រាវភាគច្រើនគេប្រើជាជីទ្រាប់បាត មានជីអាម៉ូនីញ៉ូមស៊ុលផាត ស៊ុបពែផូស្វាត និងប៉ូតាស្យ៉ូមស៊ុលផាត លាយជាមួយជីលាមកសត្វ ឬជីកំប៉ុស្តក្នុងកំរិត ៦-៨ តោនក្នុង១ហិចតា ។ ការដាក់ជីមិនដូចគ្នាទេ

ប្រែប្រួលទៅតាមប្រភេទដី នៃតំបន់នីមួយៗ ។ នៅតំបន់ដែលមានប្រពន្ធ័ទឹកគ្រប់គ្រាន់ដំណាំត្រាវត្រូវបានគេដាំ និងប្រមូលផលរៀងរាល់ឆ្នាំ ។

# ៧. ជំងឺ និងសត្វល្អិត

នៅលើដំណាំត្រាវគេច្រើនជួបប្រទះជំងឺដូចជា ជំងឺ Leaf blight (Phytophthora colocasiae Rac) ¦ គឺជាជំងឺដែលកើតច្រើននៅតំបន់ប៉ាស៊ីភិច វាបង្កអោយមានស្នាមមូលដូចរង្វង់នៅលើស្លឹក ជាំស្លឹក Necrote sport នៅលើសលឹកធ្វើអោយត្រាវស្រពោនបាក់រលំ ។

# ជំងឺ

## ជំងឺ Root rot

លេចឡើងនៅប្រទេសហ្គាណាក្នុងឆ្នាំ ១៩៣០ និងជំងឺ Leafhopper (Tarophgusproserpina) ជំងឺនេះលេចឡើងនៅប្រទេសឥណ្ឌូនេស៊ុី ។ មធ្យោបាយដែលប្រឆាំងទប់ទល់នឹងជំងឺនេះមាន បំបាត់ដើម ដែលមានជំនេះអោយឆាប់រហ័សដោយដកដើមចោល ឬយកដើមទៅកប់ចោល ឬដុតចោល បំបាត់នូវកាកសំណល់ក្រោយ ពេលបមូលផលបុព្វដំណាំ ធ្វើការផ្លាស់ប្តូរមុខដំណាំ សំអាតស្មៅនៅក្នុងចំការអោយបានល្អ ។

ចំពោះសត្វល្អិតដែលបំផ្លាញលើដំណាំត្រាវមានពពួកចៃ ( Aphid) ដង្កូវនៃពពួកសត្វ Gabi moth (Hippotioncelerion) ការបំផ្លាញពីសត្វនេះធ្វើអោយស្លឹកងាប់ជ្រុះ និងពពួកនេម៉ាតូត ។ មធ្យោបាយកំចាត់គឺគេប្រើថ្នាំ ម៉ាឡាធុងចំនួន ៥ស្លាបព្រា លាយជាមួយនឹងទឹក ២០លីត្រ ។

# ៨. ការប្រមូលផល

ដំណាំត្រាវអាចប្រមូលផលបាននៅពេលដែលវាមានអាយុពី ៦-៧ខែ អាស្រ័យទៅតាមប្រភេទពូជ គឺនៅពេលដែលស្លឹកត្រាវប្រែទៅជាពណ៌លឿងហើយងាប់ មុននឹងគាស់ជីកយកមើមគេត្រូវកាត់ធាង និងស្លឹកចេញ ដោយទុកប្រវែងពី ៤០-៥០ស.ម ពីដី ។គេប្រើចបជីកក្នុងការគាស់មើមត្រាវ ក្នុងការដាំផ្ទៃដីធំ គេភ្ជួររួចរើសមើមតាមក្រោយ ។ដំណាំត្រាវគេអាចផ្ទឹបទុកក្នុងរយៈពេល ២០-៣០ថ្ងៃ ក្រោយពេលដែលគេគាស់ហើយ វិធីដែលគេផ្ទឹបទុកគឺ គេគាស់មើមត្រាវអោយបានជាប់ដីខ្លះ រួចហើយយកមើមនោះដាក់បញ្ឈរជាប់ៗគ្នា ពេលតំរៀបមើមត្រាវរួចហើយ គេយកដីមកដាក់ជុំវិញគល់ត្រាវហើយយើងអាចស្រោចទឹកតិចៗ នៅពេលដែលយើងផ្ទឹបវាទុក ។ កាលណាយើងផ្ទឹបវាទុកក្នុងរយៈពេលយូរពេកមើមត្រាវអាចដុះ ដូច្នេះកាលណាយើងគាស់ហើយមិនទាន់យកទៅលក់ភ្លាម កុំផ្ទឹបវាទុកយូរពេក នាំអោយមើមត្រាវខូចគុណភាព និងលក់បានតំលៃថោក ។

## ឯកសារយោង


-ដំណាំត្រូពិចភាគ ១ អ្នកស្រីពានសុខា វិស្វករក្សេត្រវិទ្យា ១៩៩៧

-ដំណាំបន្លែ  លោកផាត់ មុនី វិស្វករក្សេត្រ សាស្ត្រ ១៩៩៤

-Memento de lAgronom ISSN 0336-3058

-LEPOTAGERTROPICAL Depot legal1979.1ertrimestreImpmerie BOUDIN .paris វិស្វករក្សេត្រវិទ្យា ១៩៩៧

ថ្ងៃទី ១

ព្រឹក

៨ h 00-៨ h ១០ ការណែនាំស្គាល់គ្នា

៨ h ១០-៨ h ២៥សំនួរសាកល្បងសមត្ថភាព

៨ h ២៥-៩ h 00ប្រវត្តិនិងស្ថានភាពដាំដុះសារៈប្រយោជន៍នៃដំណាំត្រាវ

៩ h 00-៩ h ៣០ លក្ខណៈរូបសាស្ត្រដំណាំត្រាវ **ក**.ប្រពន្ធ័រឹស. ខ.ដើម .

៩ h ៣០-៩ h ៤៥ ចេញលេញ អាហាសំរន់

៩ h ៤៥-១១ h ៣០ គ .ធាង ឃ .ផ្កា . ង.ស្លឹក . ច.មើម .

**១១ h ៣០-១ h 00សំរាក**

**ល្ងាច**

១ h 00-៣ h 00 ចុះពិនិត្យបច្ចេកទេសដាំដុះរបស់កសិករ

ការរៀបចំដី ការដាក់ជី ការដាំដុះ

៣ h 00-៣ h ១៥ ចេញលេញ អាហាសំរន់

៣h ១៥-៤ h 00 ពិភាគសរជាក្រុម សរសេរឆាត

៤ h 00-៥ h 00 សិក្ខាកាមពន្យល់គ្នាទៅវិញ ទៅ មក វេទិការ សំនួរ

ថ្ងៃទី ២

ព្រឹក

៨ h 00-៩ h00 ក .សីតុណ្ហភាព .ខ.ពន្លឺ..

៩ h 00-៩ h 30គ.របបទឹកភ្លៀង. ឃ.ដី ...

៩ h ៣០-៩ h ៤៥ ចេញលេញ អាហាសំរន់

៩ h ៤៥-១១ h ៣០ ..**បច្ចេកទេសដាំដុះ**. ក.ការៀបចំដី. ខ.ការដាំដុះ...

**១១ h ៣០-១ h 00សំរាក**

**ល្ងាច**

១ h 00-៣ h 00 ចុះពិនិត្យបច្ចេកទេសដាំដុះរបស់កសិករ

ជំងឺ សត្វល្អិត វិធាការកំចាត់

៣ h 00-៣ h ១៥ ចេញលេញ អាហាសំរន់ ៣ ៣h

១៥-៤ h 00 ពិភាគសរជាក្រុម សរសេរឆាត

៤ h 00-៥ h 00 សិក្ខាកាមពន្យល់គ្នាទៅវិញ ទៅ មក វេទិការ សំនួរ

**ថ្ងៃទី ៣**

**ព្រឹក**

៨ h 00-៩ h00 .**ពូជ.** COLOCASIA ANTIQUORUM EDDOE. .

៩ h 00-៩ h 30.**ពូជ.** XANTHOSOMA SAGITTIFOLIUM .

៩ h ៣0-៩ h ៤៥ ចេញលេញ អាហាសំរន់

៩ h ៤៥-១១ h ៣0 .ជំងឺនិងសត្វល្អិត. ជំងឺRoot rot.

**១១ h ៣0-១ h 00សំរាក**

**ល្ងាច**

១ h 00-៣ h ៣0 .ការប្រមូលផល

៣ h 00-៣ h ១៥ ចេញលេញ អាហាសំរន់ ៣ ៣h

១៥-៤ h 00 វេទិការ សំនួរ

៤ h 00-៥ h 00 សំនួរសាកល្បងសមត្ថភាព វាយតំលៃបញ្ចប់វគ្គ

សេចក្តីត្រូវការសំភារៈសំរាប់ការបង្រៀន

- ក្រដាសឆាត
- ហ្វឺត
- LCD